# បើគ្មានប្រជារាស្ត្រ ?

បើគ្មានការងើបឈរ នៃប្រជារាស្ត្រ ប្រឆាំងនឹងរបបផ្ដាច់ការនៅក្នុងស្រុក វាច្បាស់ជានឹងគ្មានព្រឹត្តិការណ៍ ហៅថា «៩ វិច្ឆិកា» ត្រង់ចំណុចនេះឯង ដែលរបបនៅភ្នំពេញ គេនៅមានជំនឿជាក់ច្បាស់ថា នឹងគ្មានចលនាប្រជាករ ងើបប្រឆាំងនឹងពួកគេបាន ព្រោះគេប្រើគ្រប់មធ្យោបាយសំរាប់សម្លុតស្មារតីអស់ជនខ្មែរ តាមការធ្វើគាបគៀតទៅលើសកម្មជន និង មន្ត្រីមូលដ្ឋានមួយចំនួន នៃគណបក្សសង្គ្រោះជាតិ។ មួយវិញទៀតពួកមន្ត្រីថ្នាក់ដឹកនាំជាតិ នៃគណបក្ស ជាអតីតតំណាងរាស្ត្រក្ដីជាមន្ត្រីជាន់ខ្ពស់ក្ដី នៅភ្នំពេញ ក៏នាំគ្នាសម្ងំ ចាំមើលការវិវត្តន៏នៃព្រឹត្តិការណ៍ ដូចបក្សីជាប់គប់ ក៏ដូចលោក កឹម សុខា ដេកអង្គុយរាប់ថ្ងៃ ចាំ ហ៊ុន សែន ដោះលែងពីទ្រុងមាស។ សព្វថ្ងៃនេះអ្នកទាំងនោះ ទុកខ្លួនជាជនរងគ្រោះ នាំគ្នារស់ដោយសុខាហើយ ហាក់បីទុក បេសកកម្មសង្គ្រោះជាតិរបស់ខ្លួនជាគ្រោះថ្នាក់ដាច់ខាតដល់ខ្លួនទៅវិញ។ មិនតែប៉ុណ្ណោះ បើមាននរណាធ្វើសកម្មភាពប្រឆាំងនឹងរបបផ្ដាច់ការ គេនាំគ្នាទុកជាយុទ្ធសាស្ត្រមិនល្អ ហើយដើរគេចឱ្យឆ្ងាយ ព្រោះវាអាចនាំមក នូវភាពចង្រៃដល់ខ្លួន។ រស់ក្នុង សុខា និង ទុក្ខា ចំពោះអ្នកទាំងនោះ វាដូចសុភាសិតខ្មែរចារថា «ដេកផ្សំដួល - រមួលផ្សំគ្រេច»។ ចរិត បែបនេះ វាមិនអាចលាក់ពុតបាន នៅក្នុងការតស៊ូនយោបាយ ដើម្បី សង្គ្រោះជាតិពីរបបផ្ដាច់ការបានទេ៕

ឧប សៅ សទ្ធា	គំនិត	២៥ តុលា ២០១៩